ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ជេ អេស ឌី ថេកស្តាយ(ខេមបូឌា)
J S D TEXTILE (CAMBODIA) CO.,LTD

# កំណត់ហេតុប្រជុំ និងកិច្ចព្រមព្រៀង

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៣រសៀល០០នាទី មានតំណាងក្រុមហ៊ុន ជេ អេស ឌី ថេកស្តាយ (ខេមបូឌា) បានបើកអង្គប្រជុំនៅការិយាល័យរបស់ក្រុមហ៊ុនដែលដឹកនាំប្រជុំដោយ លោកសុខ ពិសិដ្ឋ មុខងារជាប្រធានរដ្ឋបាលប្រចាំរោងចក្រ ជេ អេស ឌី ថេកស្តាយ (ខេមបូឌា) ។

កម្មវត្ថុ ៖ ការប្រជុំស្តីអំពីការរៀបចំ ព្យួរកិច្ចសន្យាការងារ កម្មករ-និយោជិត មានរយៈពេលចំនួន១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១។

១-តំណាងរោងចក្រ លោកសុខ ពិសិដ្ឋ តួនាទីជាប្រធានរដ្ឋបាលជាបឋម សូមធ្វើការណែនាំ និងលើកអំពីបញ្ហា រោងចក្រខ្វះការបញ្ជាទិញពីអតិថិជន ដូច្នេះរោងចក្រសម្រេចរៀបចំអោយកម្មករ-និយោជិត ចំនួន៥៥នាក់ (ស្រី៥១នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន១០៩៦នាក់ (ស្រី៨៨៨នាក់) ព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ដល់ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១។ រោងចក្រនឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួនទឹកប្រាក់២០ដុល្លាអាមេរិកក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ១៥ថ្ងៃ ដោយយោងតាមប្រកាសលេខ ០៩៥/២០ ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ហើយរោងចក្រនឹងបើកប្រាក់ឧបត្ថម្ភជូនដល់កម្មករនិយោជិត នៅថ្ងៃទី០៨ នៃខែបន្ទាប់ (គឺថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១)។

២-ក្រោយពីបានពិភាក្សាគ្នា ប្រកបដោយបរិយាកាសរីករាយមក បានសម្រេចលទ្ធផល ដូចខាងក្រោម ៖ ក្រុមហ៊ុន និងរវាង តំណាងប្រតិភូបុគ្គលិកពេញសិទ្ធិ និងតំណាងសហជីពយុវជនខ្មែរ និងតំណាងសហជីពកម្ពុជាអាស៊ាន តំណាងអោយកម្មករ-និយោជិតទាំងអស់ យល់ស្របនិងធ្វើកិច្ចព្រមព្រៀងទទួលនូវការព្យួរកិច្ចសន្យាការងារ ដែលរោងចក្ររៀបចំ កាលបរិច្ឆេទកំណត់បើកប្រាក់ឧបត្ថម្ភដូចខាងលើ រួមទាំងអនុវត្តន៍ និងទទួលបាននូវអត្ថប្រយោជន៍ តាមសេចក្តីប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**តំណាងប្រតិភូបុគ្គលិកពេញសិទ្ធិ និងតំណាងសហជីព**

លោក-ថោង មុនី
លោកស្រី-គិន មុំ
លោក-ឡុង វុទ្ធី
លោក-លី ឡុង
លោក-មាស ចន្ទ្រា
លោក-វណ្ណ រដ្ឋា
លោកស្រី-ពែល វុន
លោក-ជឹម ខ្នា

**តំណាងក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា J S D TEXTILE(CAMBODIA) CO.,LTD ផ្នែករដ្ឋបាល H.R DEPARTMENT ជេអេសឌី ថេកស្តាយ (ខេមបូឌា)

សុខ ពិសិដ្ឋ

扫描全能王 创建